សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ROYAL UNIVERSITY OF PHNOM PENH

# ផែនការយុទ្ធសាស្ត្រ
# ការិយាល័យធានាគុណភាព
# ២០២៤-២០៣០

## ការបង្កើតវប្បធម៌គុណភាព

QAO
2024-2030

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# ការិយាល័យធានាគុណភាព
# ផែនការយុទ្ធសាស្ត្រ ២០២៤-២០៣០

## ការបង្កើតវប្បធម៌គុណភាព

### ព័ត៌មានប្រតិបត្តិសង្ខេប

គោលដៅទី៤៖ធានាបំពេញឱ្យបាន
តាមស្តង់ដាគុណភាពអប់រំ

គោលដៅទី៥៖ផ្តល់អានុភាព
បច្ចេកវិទ្យាសម្រាប់កិច្ចការ
ធានាគុណភាព




គោលដៅទី២៖ជំរុញការលើក
កម្ពស់វប្បធម៌កែលម្អគុណ
ភាពជាប្រចាំ

គោលដៅទី៣៖ពង្រឹងការចូលរួម
របស់និស្សិត និងភាគីពាក់ព័ន្ធ

គោលដៅទី១៖លើកកម្ពស់គុណភាពការអប់រំ
និងសុចរិតភាព

# អារម្ភកថា

## សាកលវិទ្យាធិការ និងជាប្រធានគណៈកម្មការធានាគុណភាព

ផែនការយុទ្ធសាស្ត្រឆ្នាំ២០២៤-២០៣០ របស់របស់ការិយាល័យធានាគុណភាពគឺជាសូចនាករមួយជួយតម្រង់ទិស និងលើកកម្ពស់គុណភាពកម្មវិធីសិក្សាសាកលវិទ្យាល័យរបស់យើងទាំងក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត។ ឆ្លៀតឱកាសនេះ ខ្ញុំចង់បញ្ជាក់អំពីសារៈសំខាន់នៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់យើងក្នុងការចូលរួមលើកកម្ពស់គុណភាពការសិក្សា និងប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមនានារបស់យើង។ ក្នុងន័យនេះ ផែនការយុទ្ធសាស្ត្រនេះមិនមែនគ្រាន់តែជាឯកសារទេ តែវាគឺជាចក្ខុវិស័យឆ្លុះបញ្ចាំងទិសដៅ និងប្លង់មេដែលបានរចនាឡើងដើម្បីជំរុញកិច្ចការធានាគុណភាព និងប្រសិទ្ធភាពនៃអង្គភាពរបស់យើងនៅក្នុងទិដ្ឋភាពនៃការវិវត្តដែលឈានទៅរកការសម្រេចសកម្មភាពដែលបានកំណត់ និងការសម្រេចចិត្តលើកិច្ចការដែលត្រូវធ្វើជាបន្ទាន់ និងបន្តបន្ទាប់ក្នុងពេលប៉ុន្មានឆ្នាំខាងមុខនេះ។

ការប្តេជ្ញាចិត្តរបស់យើងចំពោះការធានាគុណភាពនឹងជាមូលដ្ឋានគ្រឹះនៃភាពជោគជ័យរបស់យើង នៅពេលដែលយើងអាចដោះស្រាយភាពស្មុគស្មាញទាំងនេះ។ ផែនការយុទ្ធសាស្ត្រនេះបង្ហាញពីគោលដៅ យុទ្ធសាស្ត្រ និងគំនិតផ្តួចផ្តើមដែលមានគោលបំណងច្បាស់លាស់ក្នុងការជំរុញវប្បធម៌កែលម្អគុណភាពជាប្រចាំ នវានុវត្តន៍ និងគណនេយ្យភាព។

ចំណុចសំខាន់ៗនៃផែនការយុទ្ធសាស្ត្រនេះ គឺតម្រូវឱ្យយើងទាំងអស់គ្នាយកចិត្តទុកដាក់ចូលរួមកិច្ចសហប្រតិបត្តិការ។ យើងទទួលស្គាល់ថាការសម្រេចបាននូវគោលបំណងទាំងឡាយ តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នា និងមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ រួមទាំងបុគ្គលិកអប់រំ ដៃគូ និងសហគមន៍របស់យើង។ តាមរយៈការធ្វើការរួមគ្នា យើងអាចធានាថាកម្មវិធីសិក្សារបស់យើងនឹងមិនគ្រាន់តែបំពេញបានស្តង់ដាគុណភាពក្នុងកម្រិតជាតិ តំបន់ ប៉ុន្តែថែមទាំងផ្តល់នូវអត្ថប្រយោជន៍ជាក់ស្តែងដល់និស្សិតទាំងអស់ដែលបានសិក្សា ក្នុងគ្រឹះស្ថានរបស់យើងផងដែរ។

ខ្ញុំសូមលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលរួមសហការឱ្យបានសកម្ម ក្នុងការរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រធានាគុណភាពនេះឱ្យទទួលបានជោគជ័យ និងប្រកបដោយការប្តេជ្ញាចិត្ត។ ការរួមចំណែកទាំងស្មារតី និងជំនាញរបស់លោកអ្នកគឺមានតម្លៃមិនអាចកាត់ថ្លៃបាន នៅពេលដែលយើងព្យាយាមសម្រេចចំណុចដែលត្រូវការកែលម្អ និងអនុវត្តបានល្អបំផុតរួមគ្នា។ សរុបសេចក្តីមក យើងអាចបង្កើតឱ្យមានបរិយាកាសសម្រាប់ការធានាគុណភាពអប់រំដែលមិនមែនគ្រាន់តែជាមុខងារប៉ុណ្ណោះទេ ប៉ុន្តែជាទិដ្ឋភាពមូលដ្ឋាននៃក្រមសីលធម៌ និងការទទួលខុសត្រូវរបស់សាកលវិទ្យាល័យរបស់យើង។

សូមអរគុណចំពោះការលះបង់ និងទឹកចិត្តដែលមិនរាថយរបស់លោកអ្នក។ យើងនឹងរួមគ្នាធ្វើឱ្យចក្ខុវិស័យរបស់យើងក្លាយជាការពិត។

សាស្ត្រាចារ្យ **ជេត ជាលី**

សាកលវិទ្យាធិការ និងជាប្រធានគណៈកម្មការធានាគុណភាព

# ផែនការយុទ្ធសាស្ត្រ ២០២៤-២០៣០

## I. សេចក្តីផ្តើម

ផែនការយុទ្ធសាស្ត្រនៃការិយាល័យធានាគុណភាពបានកំណត់ចក្ខុវិស័យ បេសកកម្ម គុណតម្លៃស្នូល គោលដៅ គោលបំណង សកម្មភាព និងសូចនាករដែលបង្ហាញពីដំណើររបស់ការិយាល័យពីឆ្នាំ២០២៤ ដល់ឆ្នាំ២០៣០ និងផ្សព្វផ្សាយប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃនៅក្នុងសាកលវិទ្យាល័យ។ ផែនការនេះត្រូវបានបង្កើតឡើងដើម្បីគាំទ្រ និងស្របតាមចក្ខុវិស័យ និងគោលដៅដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រ១០ឆ្នាំរបស់ ស.ភ.ភ.ព។ ការគ្រប់គ្រងកិច្ចការធានាគុណភាពនៅកម្រិតសាកលវិទ្យាល័យមានគោលបំណងបំពេញតាមស្តង់ដាជាតិដែលកំណត់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា ACC និងស្តង់ដាតំបន់ AUN-QA។ ការពង្រឹងការធានាគុណភាពនៅកម្រិតកម្មវិធីផ្តោតលើស្វ័យកែលម្អផ្ទៃក្នុង ការរៀបចំស្វ័យវាយតម្លៃ និងការរៀបចំកម្មវិធីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលស្គាល់គុណភាពក្នុងកម្រិតតំបន់ AUN-QA ។

ការគាំទ្រពេញទំហឹងពីសាកលវិទ្យាល័យ និងបទពិសោធន៍កិច្ចធានាគុណភាពប្រកបដោយសមត្ថភាពរបស់ការិយាល័យធានាគុណភាពគឺជាកម្លាំងចលករជំរុញដ៏សំខាន់ក្នុងការបំពេញបេសកកម្មរបស់សាកលវិទ្យាល័យឱ្យសម្រេចជោគជ័យ។ ដូច្នេះវិសាលភាពនៃផែនការយុទ្ធសាស្ត្ររបស់ការិយាល័យធានាគុណភាពនេះរួមមាន៖

- ការលើកកម្ពស់សមត្ថភាពបុគ្គលិកធានាគុណភាពផ្ទៃក្នុងដែលជាកម្លាំងគាំទ្រសកម្មភាពដើម្បីបង្កើតវប្បធម៌គុណភាព និងនិរន្តរភាពប្រព័ន្ធ
- ការពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃគុណភាព
- ការកែលម្អការធានាគុណភាពនៅកម្រិតដេប៉ាតឺម៉ង់
- ការលើកកម្ពស់ឧត្តមភាពសិក្សាស្របតាមស្តង់ដាជាតិ និងតំបន់
- ការបង្កើតប្រព័ន្ធឌីជីថល និងថ្នាលសម្រាប់ការត្រួតពិនិត្យសូចនាករសំខាន់ៗ (KPIs) ការគ្រប់គ្រងកិច្ចការធានាគុណភាពផ្ទៃក្នុង ការគ្រប់គ្រងទិន្នន័យ ការវាយតម្លៃកម្មវិធី ការសិក្សាតាមដានការសិក្សានិស្សិត និងគោលការណ៍បណ្តឹងតវ៉ារបស់និស្សិត និងបុគ្គលិក។

## ចក្ខុវិស័យ

ដើម្បីក្លាយជាអ្នកត្រួតពិនិត្យ វាយតម្លៃលើការធានាគុណភាពឈានមុខ អាចទុកចិត្តក្នុងប្រព័ន្ធគ្រប់គ្រងគុណភាព ជំរុញវប្បធម៌កែលម្អគុណភាពជាប្រចាំ និងឧត្តមភាពក្នុងវិស័យអប់រំ ការស្រាវជ្រាវ និងការចូលរួមសហគមន៍ ដើម្បីធានាថា ស.ភ.ភ.ព នៅតែជាអ្នកនាំមុខក្នុងការអប់រំឧត្តមសិក្សា និងឆ្លើយតបតម្រូវការដែលកំពុងរីកចម្រើនរបស់និស្សិត និងសង្គម។

## បេសកកម្ម

បេសកកម្មរបស់ការិយាល័យធានាគុណភាពគឺដើម្បីផ្តល់នូវក្របខណ្ឌការធានាគុណភាពគ្រប់ជ្រុងជ្រោយ ដែលគាំទ្រដល់សុចរិតភាពនៃការសិក្សា ភាពជោគជ័យរបស់និស្សិត និងការទទួលខុសត្រូវក្នុងស្ថាប័ន តាមរយៈការលើកកម្ពស់ការអនុវត្តប្រកបដោយនវានុវត្តន៍ និងការចូលរួមពីភាគីពាក់ព័ន្ធ។ ដូច្នេះ ការិយាល័យធានាគុណភាពធ្វើការសហការជាមួយគ្រប់មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ ការិយាល័យ និងអង្គភាពចំណុះ ស.ភ.ភ.ព ដើម្បីៈ

- លើកកម្ពស់ឧត្តមានុវត្តន៍ក្នុងការគ្រប់គ្រងគុណភាពជាមួយភាគីពាក់ព័ន្ធ ស.ភ.ភ.ព
- ដើរតួជាអ្នកត្រួតពិនិត្យ វាយតម្លៃ និងអ្នកប្រឹក្សាយោបល់កិច្ចការគ្រប់គ្រងគុណភាពផ្ទៃក្នុងរបស់ ស.ភ.ភ.ព
- លើកកម្ពស់គុណភាពនៃកម្មវិធីអប់រំ និងការគ្រប់គ្រងការធានាគុណភាពផ្ទៃក្នុងរបស់សាកលវិទ្យាល័យ
- រៀបចំកម្មវិធីសិក្សារបស់ ស.ភ.ភ.ព ឱ្យមានការទទួលស្គាល់ផ្ទៃថ្នាក់ជាតិ និងតំបន់។

## គោលដៅ

ផែនការយុទ្ធសាស្ត្រការិយាល័យធានាគុណភាព(QA) បង្ហាញពីការប្តេជ្ញាចិត្តក្នុងការធានាថានិស្សិតបញ្ចប់ការសិក្សា និងការផ្តល់សេវាកម្មស្របតាមស្តង់ដាគុណភាព ទំនុកចិត្ត ភាពជឿជាក់ និងការប្រតិបត្តិប្រកបដោយប្រសិទ្ធភាព។ គោលដៅធានាគុណភាពគឺដើម្បីធ្វើឱ្យកម្មវិធីសិក្សាទាំងអស់ឆ្លើយតប ស្តង់ដាកម្រិតខ្ពស់ តាមរយៈជំរុញការកែលម្អគុណភាពជាប្រចាំ និងបំពេញតម្រូវការរបស់និស្សិតបុគ្គលិកអប់រំ និយោជក និងសហគមន៍ តាមរយៈយន្តការបង្កើនដំណើរការធានាគុណភាពរបស់សាកលវិទ្យាល័យ ត្រៀមលក្ខណៈដោះស្រាយបញ្ហាប្រឈមថ្មីៗ និងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីបង្កើនប្រសិទ្ធភាពកិច្ចការប្រតិបត្តិ និងការខិតខំប្រឹងប្រែងកែលម្អគុណភាព។ ផែនការយុទ្ធសាស្ត្រនេះគឺជាផែនទីបង្ហាញផ្លូវដើម្បីណែនាំភាគីពាក់ព័ន្ធ និងដៃគូរបស់សាកលវិទ្យាល័យក្នុងការស្វែងរកឧត្តមភាពប្រកបដោយគុណភាព។ ដើម្បីសម្រេចបានគោលដៅចម្បងទាំងនេះ ការិយាល័យធានាគុណភាពនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានគោលដៅ៥ដូចខាងក្រោម ៖



**គោលដៅទី១៖ លើកកម្ពស់គុណភាពសិក្សា និងសុចរិតភាព** ៖ ដើម្បីកែលម្អ និងពង្រឹងប្រព័ន្ធត្រួត ពិនិត្យ និងវាយតម្លៃ គុណភាព គ្រប់កម្មវិធីចំណុះសាកលវិទ្យាល័យ តាមរយៈការកែលម្អគុណភាពជាប្រចាំ (CQI)។

**គោលដៅទី២៖ ជំរុញលើកកម្ពស់វប្បធម៌កែលម្អគុណភាពជាប្រចាំ** ៖ ដើម្បីគ្រប់គ្រងប្រព័ន្ធធានាគុណភាពដែលឱ្យល្អប្រសើរលើសពីស្តង់ដាជាតិដែលតម្រូវដោយឧត្តមសិក្សា។

**គោលដៅទី៣៖ ពង្រឹងការចូលរួមរបស់និស្សិត និងភាគីពាក់ព័ន្ធ** ៖ ដើម្បីជួយភាគីពាក់ព័ន្ធរបស់ ស.ភ.ភ.ព តាមរយៈស្វ័យវាយតម្លៃ ដើម្បីមានគំនិតផ្តួចផ្តើមសម្រាប់ការកែលម្អកម្មវិធីសិក្សានិងដំណើរការប្រតិបត្តិរបស់ខ្លួននិងឈានទៅរកការទទួលស្គាល់កម្រិតជាតិ និងតំបន់។

**គោលដៅទី៤៖ ធានាបំពេញឱ្យបានតាមស្តង់ដាគុណភាពអប់រំ៖** ដើម្បីធានាបានឧត្តមានុវត្តន៍នៃការធានាគុណភាពជាមួយភាគីពាក់ព័ន្ធ។

**គោលដៅទី៥៖ ផ្តល់អានុភាពបច្ចេកវិទ្យាសម្រាប់កិច្ចការធានាគុណភាព៖** ដើម្បីបង្កើតថ្នាលឌីជីថលសម្រាប់ សូចនាករសំខាន់ៗ(KPIs) ត្រួតពិនិត្យគុណភាពនៃលទ្ធផលសិក្សាដើម្បីបំពេញតាមស្តង់ដាជាតិ និងតំបន់ និងសម្រេចបានឧត្តមភាពសិក្សា។

## គុណតម្លៃស្នូល

ការិយាល័យធានាគុណភាពផ្តល់តម្លៃដោយមានការរំពឹងទុកខ្ពស់ ពីឧត្តមានុវត្តន៍ការសិក្សាដោយផ្តោតលើគណនេយ្យភាព តម្លាភាព ប្រកបដោយវិជ្ជាជីវៈ និងនិរន្តរភាព សុចរិតភាព ការផ្តល់សិទ្ធិអំណាច និងក្នុងការបញ្ចេញសកម្មភាពបំពេញបាវចនានៃ**ការបង្កើតវប្បធម៌គុណភាព**។

## II. គោលដៅយុទ្ធសាស្ត្រ និងគោលបំណង

**គោលដៅទី១ ៖ លើកកម្ពស់គុណភាពការអប់រំ និងសុចរិតភាព**

**គោលបំណង១.១ ៖** វាយតម្លៃសកម្មភាពអប់រំជាទៀងទាត់ និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាដោយផ្អែកលើនិន្នាការឧស្សាហកម្ម និងធាតុចូលពីភាគីពាក់ព័ន្ធ។

**ជំហានសកម្មភាព ៖**

- បង្កើតគោលការណ៍ណែនាំសម្រាប់ទម្រង់ត្រួតពិនិត្យកម្មវិធី។
- បង្កើតនិងអនុវត្តដំណើរការត្រួតពិនិត្យកម្មវិធីឱ្យបានទូលំទូលាយគ្រប់កម្មវិធី។

- ផ្ដល់ការបណ្ដុះបណ្ដាលដល់បុគ្គលិកអប់រំអំពីស្វ័យវាយតម្លៃប្រកបដោយប្រសិទ្ធភាពខ្ពស់។
- ស្វែងរកអ្នកត្រួតពិនិត្យខាងក្រៅវាយតម្លៃកម្មវិធីដែលសក្ដានុពលឬបានជ្រើសរើស។

**គោលបំណង១.២ ៖** អនុវត្តក្របខណ្ឌការវាយតម្លៃគ្រប់ជ្រុងជ្រោយលើលទ្ធផលសិក្សារំពឹងទុកសម្រាប់គ្រប់មុខវិជ្ជាទាំងអស់ត្រឹមឆ្នាំ២០៣០។

**ជំហានសកម្មភាព ៖**

- ពិនិត្យការផ្ទៀងផ្ទាត់លទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជាជាមួយនឹងគោលដៅរបស់ដេប៉ាតឺម៉ង់ និងស្ថាប័ន។
- ប្រើប្រាស់មតិកែលម្អពីការវាយតម្លៃមុខវិជ្ជា ដើម្បីបង្កើនប្រសិទ្ធភាពការបង្រៀន និងការវាយតម្លៃ។

**គោលដៅទី២ ៖ ជំរុញការលើកកម្ពស់វប្បធម៌កែលម្អគុណភាពជាប្រចាំ**

**គោលបំណង២.១ ៖** កំណត់និយាមបទដ្ឋានរបស់ស្ថាប័ននិងសូចនាករអនុវត្តន៍សម្រាប់ការកែលម្អគុណភាពនៅឆ្នាំ ២០២៦។

**ជំហានសកម្មភាព ៖**

- រៀបចំអភិវឌ្ឍលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃការអនុវត្ត និងការទទួលខុសត្រូវរបស់បុគ្គលិកអប់រំ និងគណៈកម្មការធានាគុណភាពផ្ទៃក្នុង។
- រៀបចំកាលវិភាគប្រមូលទិន្នន័យជាប្រចាំសម្រាប់ចងក្រងរបាយការណ៍ និងកែលម្អផែនការគុណភាព។
- បង្កើតយន្តការសម្រាប់បុគ្គលិកអប់រំ និងការអភិវឌ្ឍសមត្ថភាពបុគ្គលិកស្របតាមគោលដៅការធានាគុណភាព។
- អនុវត្តវដ្ដនៃការប្រមូលមតិត្រឡប់ច្បាស់លាស់ពីភាគីពាក់ព័ន្ធទាំងអស់រួមទាំងនិស្សិតកំពុងសិក្សា និងអតីតនិស្សិតដែលបានបញ្ចប់ការសិក្សា។

**គោលបំណង២.២ ៖** អភិវឌ្ឍនិងរៀបចំការបណ្ដុះបណ្ដាលស្ដីពីការធានាគុណភាពសម្រាប់សមាជិកមហាវិទ្យាល័យ ដេប៉ាតឺម៉ង់ និងបុគ្គលិកធានាគុណភាពផ្ទៃក្នុងជារៀងរាល់ឆ្នាំ។

**ជំហានសកម្មភាព ៖**

- កំណត់ប្រធានបទសំខាន់ៗទាក់ទងកិច្ចអប់រំសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ។
- ប្រើប្រាស់អ្នកជំនាញកិច្ចធានាគុណភាពខាងក្នុង និងខាងក្រៅ ដើម្បីជួយសម្រួលដល់សិក្ខាសាលា។

**គោលដៅទី៣ ៖ ពង្រីកការចូលរួមរបស់និស្សិត និងភាគីពាក់ព័ន្ធ**

**គោលបំណង៣.១ ៖** បង្កើនការប្រើប្រាស់ការវិភាគទិន្នន័យដើម្បីវិនិច្ឆ័យប្រសិទ្ធភាពដំណើរការប្រតិបត្តិកិច្ចការធានាគុណភាពនៅឆ្នាំ២០២៨។

**ជំហានសកម្មភាព ៖**

- អនុវត្តយុទ្ធសាស្ត្រសម្រាប់ការកែលម្អស្ថានភាពសិក្សានិស្សិត អត្រាបញ្ចប់ការសិក្សា និងតាមដានលទ្ធភាពទទួលបានការងារ។
- លើកកម្ពស់ការរៀនសូត្រតាមបែបសកម្ម និងវិធីសាស្ត្របង្រៀនបែបនវានុវត្តន៍។
- ជំរុញការផ្តល់សេវាកម្មគាំទ្រនិស្សិតមានភាពងាយស្រួល និងដំណើរការប្រកបដោយប្រសិទ្ធភាព។
- ផ្តល់វេទិកាសម្រាប់និស្សិតដើម្បីបញ្ចេញទស្សនៈអំពីបញ្ហាគុណភាពអប់រំ។

**គោលបំណង៣.២ ៖** ធ្វើការស្ទង់មតិការពេញចិត្តរបស់ភាគីពាក់ព័ន្ធប្រចាំឆ្នាំ ដើម្បីវាស់ស្ទង់ការយល់ឃើញពីគុណភាពនៅសាកលវិទ្យាល័យដោយផ្តើមនៅឆ្នាំ២០២៥ទៅ។

**ជំហានសកម្មភាព ៖**

- ធ្វើស្វ័យវាយតម្លៃលើការបំពេញភារកិច្ចបុគ្គលិកប្រចាំឆ្នាំ
- ធ្វើការស្ទង់មតិរៀងរាល់ពីរឆ្នាំម្តង ដើម្បីប្រមូលមតិកែលម្អលើការអនុវត្តកិច្ចការគុណភាព និងចំណុចត្រូវដែលកែកែលម្អ ។
- វិភាគលទ្ធផលនៃការស្ទង់មតិដើម្បីកំណត់ចំណុចខ្លាំង និងចំណុចត្រូវដែលកែកែលម្អ។
- ចែករំលែករបកគហើញជាមួយភាគីពាក់ព័ន្ធ ដើម្បីរៀបចំបង្កើតផែនការសកម្មភាព។
- បង្កើនពិន្ទុពេញចិត្តដែលមានស្រាប់របស់ភាគីពាក់ព័ន្ធ យ៉ាងហោចណាស់ឱ្យបាន២០% រហូតដល់ឆ្នាំ ២០៣០។

**គោលដៅទី៤ ៖ ធានាបំពេញឱ្យបានតាមស្តង់ដាគុណភាពអប់រំ**

**គោលបំណង៤.១ ៖** ពិនិត្យ និងផ្ទផ្ទងការអនុវត្តកិច្ចអប់រំរបស់ស្ថាប័នជាមួយនឹងនិយាមបទដ្ឋាននៃស្ថាប័នទទួលស្គាល់កម្មវិធីផ្ទៃក្នុងថ្នាក់ជាតិ និងថ្នាក់តំបន់។

**ជំហានសកម្មភាព ៖**

- លើកកម្ពស់គុណភាពឱ្យស្របតាមការប្រែប្រួលនៅក្នុងនិយាមដ្ឋានការទទួលស្គាល់គុណភាព។
- បង្កើតដំណើរការវិនិច្ឆ័យគុណភាពផ្ទៃក្នុង ដើម្បីធានាបានដំណើរប្រតិបត្តិឆ្លើយតបស្តង់ដា។

- រៀបចំយន្តការទទួលស្គាល់ស្នាដៃបំពេញការងារគុណភាព និងប្រគល់រង្វាន់ដល់ក្រុមដែលបង្ហាញពីការប្រតិបត្តិប្រកបដោយគុណភាពលេចធ្លោរប្រចាំឆ្នាំ។

**គោលបំណង៤.២ ៖** រៀបចំវគ្គការទទួលស្គាល់គុណភាពទាំងអស់ឱ្យផុសផុលតាមរយៈដំណើរការចងក្រងឯកសារ និងពិនិត្យយ៉ាងហ្មត់ចត់ជាប្រចាំ ដោយចាប់ផ្តើមមួយឆ្នាំមុនពេលដំណើរការចុះវាយតម្លៃទទួលស្គាល់គុណភាព ។

**ជំហានសកម្មភាព ៖**

- អនុវត្តវគ្គគំរូសុពលភាពនៃការធានាគុណភាពឱ្យបានទូលំទូលាយសម្រាប់ដេប៉ាតឺម៉ង់ទាំងអស់។
- លើកទឹកចិត្តឱ្យមានកិច្ចសហការឆ្លងដេប៉ាតឺម៉ង់ មហាវិទ្យាល័យ ដោយផ្តោតលើគំនិតផ្តួចផ្តើមប្រកបដោយគុណភាព តាមរយៈសិក្ខាសាលា និងវេទិកាពិភាក្សាការធានាគុណភាពជាទៀងទាត់។

**គោលដៅទី៥ ៖ ផ្តល់អានុភាពបច្ចេកវិទ្យាសម្រាប់កិច្ចការធានាគុណភាព**

**គោលបំណង៥.១ ៖** កំណត់សញ្ញាណទិន្នន័យនិងដាក់ឱ្យប្រើប្រាស់ឧបករណ៍ស្វ័យប្រវត្តិកម្មសម្រាប់ដំណើរការកិច្ចការធានាគុណភាពចាប់ពីឆ្នាំ២០២៦ ដើម្បីកាត់បន្ថយកំហុសអចេតនាដោយដៃ និងបង្កើនប្រសិទ្ធភាពការងារ។

**ជំហានសកម្មភាព ៖**

- ប្រើប្រាស់ការវិភាគទិន្នន័យ ដើម្បីរៀបចំដំណើរការកិច្ចការធានាគុណភាំពនិងសម្រាប់ការសម្រេចចិត្ត។
- ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការរៀនសិក្សា(LMS) ដែលអាចអាចបង្កើនបទពិសោធន៍នៃការរៀននិងការបង្រៀន។
- អភិវឌ្ឍធនធានកិច្ចការធានាគុណភាពតាមអនឡាញសម្រាប់លើកកម្ពស់ការយល់ដឹងការធានាគុណភាព និងការបណ្តុះបណ្តាល។
- ប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យាទំនើបសម្រាប់ដំណើរការកិច្ចការធានាគុណភាព( ឧ. ស្វ័យប្រវត្តិកម្មបញ្ញាសប្បនិម្មិត AI )។

**គោលបំណង៥.២ ៖** អនុវត្តមជ្ឈមណ្ឌលប្រព័ន្ធគ្រប់គ្រងកិច្ចការធានាគុណភាពនៅឆ្នាំ២០២៧ ដើម្បីកែលម្អការតាមដាន និងរាយការណ៍អំពីស្ថានភាពគុណភាព។

**ដំណាក់កាលសកម្មភាព៖**

- បង្កើតថ្នាលឌីជីថលសម្រាប់ការស្រាវជ្រាវលទ្ធភាពរកការងារធ្វើក្រោយបញ្ចប់ការសិក្សាយន្តការបណ្ដឹងតវ៉ារបស់និស្សិត និងប្រព័ន្ធត្រួតពិនិត្យតាមដាន (M&E)។
- តាមដានកំណើនភាគរយនៃដំណើរការកិច្ចការធានាគុណភាពដែលស្របតាមតម្រូវការឧស្សាហកម្ម។
- បង្កើនចំនួនសមាជិកអប់រំតាមមហាវិទ្យាល័យ ដេប៉ាតឺម៉ង់ឱ្យទទួលបានការបណ្ដុះបណ្ដាលលើកិច្ចការអនុវត្តធានាគុណភាព។
- បង្កើតថ្នាលគ្រប់គ្រងសូចនាករគន្លឹះសំខាន់ៗ(KPIs) ដើម្បីបង្កើនពិន្ទុពេញចិត្តរបស់ភាគីពាក់ព័ន្ធ។
- បង្កើតសូចនាករគន្លឹះសំខាន់ៗ(KPIs) ដើម្បីវាស់វែងវឌ្ឍនភាពឆ្ពោះទៅរកគោលដៅយុទ្ធសាស្ត្រ។

## III. សូចនាករធានាគុណភាព និងសកម្មភាពសំខាន់ៗ

សកម្មភាពយុទ្ធសាស្ត្ររបស់ការិយាល័យធានាគុណភាពរៀបចំឡើងសម្រាប់គាំទ្រដំណើរការកែលម្អសំខាន់ៗរបស់ប្រតិបត្តិការ រចនាសម្ព័ន្ធ និងវប្បធម៌សាកលវិទ្យាល័យដែលនឹងត្រូវអនុវត្តជាជំហានដំបូងនៃផែនការនេះ ហើយបន្តត្រួតពិនិត្យនិងធ្វើឱ្យប្រសើរឡើងទៅតាមដំណាក់កាលចាំបាច់នៅពេលដែលផែនការនេះដាក់ចេញសម្រាប់អនុវត្ត។ សូចនាករគោលដៅសំខាន់ៗសម្រាប់យុទ្ធសាស្ត្រឆ្នាំ ២០៣០ គឺ៖

| ល.រ | សូចនាករ | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | 2040 | 2050 |
|---|---|---|---|---|---|---|---|---|---|---|
| 1 | ដេប៉ាតឺម៉ង់រៀបចំរបាយការណ៍ស្វ័យវាយតម្លៃ(SAR)មានគុណភាព | 65% | | | 75% | | | 100% | | |
| 2 | កែលម្អសមាសធាតុកម្មវិធីសិក្សា(PLOs, CLOs, ILOs) ឱ្យត្រូវតាមទម្រង់ប្រទាក់ក្រឡាជាមួយ (EP, GAs, PEOs) | | 45% | | | 75% | | 100% | | |
| 3 | រៀបចំកម្មវិធីសិក្សាឱ្យទទួលបានការវាយតម្លៃកម្រិតតំបន់ (AUN-QA) ឬពីភ្នាក់ងារវាយតម្លៃអន្តរជាតិ | | | 2 | 1 | 2 | 1 | | | |
| 4 | រៀបចំកម្មវិធីសិក្សាឱ្យទទួលបានការវាយតម្លៃគុណភាពផ្ទៃក្នុង (RUPP-IQA) | | 10% | | 50% | | 70% | 100% | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 5 | រៀបចំកម្មវិធីសិក្សាឱ្យស្របតាមទម្រង់ការអប់រំផ្អែកលើលទ្ធផល (OBE) | 1 | 3 | 8 | 16 | 26 | 30 | 70% | | |
| 6 | រៀបចំការវាយតម្លៃគុណភាពតាមបែបឌីជីថលនីយកម្ម(កំណត់ការងារត្រូវតាមជំនាញធនធាន) | | | | | | | 1 | | |
| 7 | បង្កើតថ្នាលគ្រប់គ្រងសូចនាករគន្លឹះសំខាន់ៗ (KPIs) ក្នុងប្រព័ន្ធធានាគុណភាពផ្ទៃក្នុង | | | | 1 | | | | | |
| 8 | បង្កើតថ្នាលឌីជីថលសម្រាប់យន្តការបណ្តឹងតវ៉ានិស្សិតនិងបុគ្គលិក | | | | | 1 | 1 | | | |
| 9 | ពិនិត្យផ្ទៀងផ្ទាត់ការអនុវត្តផែនការយុទ្ធសាស្ត្រធានាគុណភាពផ្ទៃក្នុង (IQA) ឡើងវិញ | | | 1 | | | | | | |
| 10 | អភិវឌ្ឍប្រព័ន្ធវាយតម្លៃការងារបុគ្គលិក | | | 1 | | | | | | |
| 11 | បង្កើតថ្នាលឌីជីថលសម្រាប់សិក្សាលទ្ធភាពរកការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សា (Tracer Study) | | | | | 1 | | | | |
| 12 | អនុវត្តប្រព័ន្ធវាយតម្លៃគុណភាពផ្ទៃក្នុងសម្រាប់ត្រួតពិនិត្យនិងវាយតម្លៃ (M&E) | | | | | | 1 | | | |
| 13 | ចំណាត់ថ្នាក់សាកលវិទ្យាល័យក្នុងប្រព័ន្ធអន្តរជាតិ (THE&QS) | | | | | | | THE | QS | |
| 14 | កម្ពុជាក្លាយជាប្រទេសចំណូលកម្រិតខ្ពស់៖ ស.ភ.ភ.ព ត្រូវមានបុគ្គលិកអប់រំកម្រិតបណ្ឌិត៤៥% | | | | | | 25% | | | 45% |

## វិធានប្រើប្រាស់ចំណេះដឹងសម្រាប់គុណតម្លៃស្នូល

ការអនុវត្ត ៖ បន្តកែលម្អលើកម្ពស់ការអនុវត្តការអប់រំនិងបច្ចុប្បន្នកម្មឯកសារឱ្យស្របតាមនិយាម បទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យនៃគុណភាព។

ឧត្តមភាព ៖ ខិតខំដើម្បីសម្រេចឱ្យបានសមត្ថភាព ប្រសិទ្ធភាព និងគុណភាពខ្ពស់បំផុតក្នុងការរៀន ការបង្រៀន និងការស្រាវជ្រាវ ។

គណនេយ្យភាព ៖ ដើម្បីផ្តល់ព័ត៌មានដែលអាចជឿទុកចិត្តបានលើប្រតិបត្តិការរបស់ស្ថាប័នតាមរយៈ សកម្មភាពជាច្រើនរួមមាន ការវាយតម្លៃ សវនកម្មហិរញ្ញវត្ថុ ការត្រួតពិនិត្យកម្មវិធីសិក្សា ការស្រាវជ្រាវទីផ្សារ កិច្ចសហប្រតិបត្តិការអន្តរជាតិ ការអនុវត្តចំណេះដឹង និងជំនាញ ការទទួលស្គាល់ការរួមចំណែកនិងការទទួលខុសត្រូវរបស់បុគ្គល និងដេប៉ាតឺម៉ង់ ។

តម្លាភាព ៖ ដើម្បីផ្តល់ព័ត៌មានអំពីលទ្ធផលសិក្សាដែលអាចទុកចិត្តបានសម្រាប់ភាគីពាក់ព័ន្ធរបស់សាកលវិទ្យាល័យអំពីអ្វីដែលការិយាល័យធានាគុណភាពកំពុងប្រតិបត្តិ និងផ្តល់ភាពងាយស្រួលសម្រាប់បណ្តាញធានាគុណភាពផ្ទៃក្នុង ក្រុមប្រឹក្សាធានាគុណភាពផ្ទៃក្នុង និងភាគីពាក់ព័ន្ធនៃ ស.ភ.ភ.ព ដើម្បីពិនិត្យមើលសកម្មភាពទាំងឡាយដែលត្រូវបានអនុវត្ត។

វិជ្ជាជីវៈ ៖ ដើម្បីប្រើប្រាស់ជំនាញ ចំណេះដឹង និងបទពិសោធន៍ល្អបំផុតសម្រាប់ជាប្រយោជន៍ដល់បុគ្គលិកអប់រំទាំងអស់ ដែលគួរតែយកចិត្តទុកដាក់ដល់ភាគីពាក់ព័ន្ធរបស់សាកលវិទ្យាល័យដោយការព្រួយបារម្ភ ការប្តេជ្ញាចិត្ត និងស្មារតីទទួលខុសត្រូវសម្រាប់អនាគតអាជីពរបស់ពួកគេ។

និរន្តរភាព ៖ ដើម្បីជំរុញផ្នត់គំនិតផ្តួចផ្តើមមិនចេះរីងស្ងួតដែលបង្កើតឡើងដោយសាកលវិទ្យាល័យនៅគ្រប់ទិដ្ឋភាពក្នុងការបំពេញបេសកកម្ម។

សុចរិតភាព ៖ ប្រកាន់ខ្ជាប់នូវគោលការណ៍ស្មោះត្រង់ និងគណនេយ្យភាពក្នុងប្រតិបត្តិការទាំងអស់ប្រកបដោយក្រមសីលធម៌ ទំនុកចិត្ត និងតម្លាភាព។

ការផ្តល់សិទ្ធិអំណាច៖ ដើម្បីលើកទឹកចិត្ត និងអនុញ្ញាតឱ្យភាគីពាក់ព័ន្ធនៃសាកលវិទ្យាល័យធ្វើការសម្រេចចិត្តក្នុងដែនសមត្ថកិច្ចការងាររបស់ខ្លួនដោយផ្តោតលើគុណភាពជាចម្បង ។

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

- មហាវិទ្យាល័យវិទ្យាសាស្ត្រ
- មហាវិទ្យាល័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រ
- មហាវិទ្យាល័យវិស្វកម្ម
- មហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍
- មហាវិទ្យាល័យអប់រំ
- វិទ្យាស្ថានភាសាបរទេស
- វិទ្យាស្ថានសិក្សាអន្តរជាតិ និងគោលនយោបាយសាធារណៈ
- ថ្នាក់ក្រោយបរិញ្ញាបត្រ
- មជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-ជប៉ុន
- មជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-កូរ៉េ
- មជ្ឈមណ្ឌលជាតិបណ្តុះធុរកិច្ចថ្មីនៃកម្ពុជា
- មជ្ឈមណ្ឌលសហប្រតិបត្តិការរវាងសាកលវិទ្យាល័យ-ឧស្សាហកម្ម

